យើងខ្ញុំទាំងអស់គ្នា ជាតំណាងអង្គការជាតិ និងអន្តរជាតិ
ដែលកំពុងបំពេញការងារដើម្បីរួមចំណែកលើកកម្ពស់
សុវត្ថិភាពចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា

**សូមគោរពជូន**

**ឯកឧត្តម ត្រាំ អ៊ីវតឹក**

**រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**

**និងជា ប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក**

ឯកឧត្តមរដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

ចាប់តាំងពីបានបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកកម្ពុជានៅឆ្នាំ២០០៥មក អត្រាអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ក្នុងយានយន្ត ១០ ០០០គ្រឿង បានថយចុះជាបន្តបន្ទាប់គឺ ពី**១៨.១នាក់** ក្នុងយានយន្ត១០ ០០០គ្រឿង ក្នុងឆ្នាំ២០០៦ មកនៅត្រឹម**១១នាក់** ក្នុងយានយន្ត ១០ ០០០គ្រឿង ក្នុងឆ្នាំ២០១០។ លទ្ធផលដែលគួរឱ្យកត់សម្គាល់ទាំងនេះ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅទូទាំងតំបន់។

ក្នុងនាមជាអង្គការជាតិ និងអន្តរជាតិ ដែលកំពុងបំពេញការងារដើម្បីលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ យើងខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះឆន្ទៈនយោបាយយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើឱ្យសម្រេចបានសមិទ្ធិផលទាំងនេះ។ ជាមួយគ្នានេះ យើងខ្ញុំក៏សូមកោតសរសើរដល់រាជរដ្ឋាភិបាល ដែលបានអនុម័តគាំទ្រលើសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិស្តីពីទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវ

គោក (ឆ្នាំ២០១១-២០២០)។ ការរៀបចំផែនការសកម្មភាពជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោករយៈពេល ១០ឆ្នាំ ព្រមទាំងការពិនិត្យមើលឡើងវិញលើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (ព្រះរាជក្រឹត្យលេខ នស/រកម/០២០៧/០០៧) ដោយតម្រូវឱ្យបញ្ចូលអ្នករួមដំណើរតាមទោចក្រយានយន្តពាក់មួកសុវត្ថិភាពនឹងក្លាយជាជំហានយ៉ាងសំខាន់ជាប្រវត្តិសាស្ត្រមួយឆ្ពោះទៅសម្រេចគោលបំណងទសវត្សរ៍របស់ខ្លួន ដើម្បីកាត់បន្ថយចំនួនអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ឱ្យបាន ៥០% និងបង្កើនការគោរពច្បាប់ដោយពាក់មួកសុវត្ថិភាពឱ្យបាន ១០០% នៅត្រឹមឆ្នាំ២០២០ខាងមុខនេះ។

ទោះជាយ៉ាងណាក្តី វិធានការជាវិជ្ជមានទាំងនេះនឹងទទួលបានជោគជ័យកាន់តែច្រើនថែមទៀត ប្រសិនបើកុមារដែលមានអាយុចាប់ពី២ឆ្នាំឡើងទៅ ត្រូវបានបញ្ចូលទៅក្នុងបទបញ្ញត្តិស្តីពីការពាក់មួកសុវត្ថិភាពក្នុងចំណោមអ្នករួមដំណើរតាមទោចក្រយានយន្តនៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ វិធានការនេះនឹងមានឥទ្ធិពលជាវិជ្ជមានលើការងាររបស់ស្ថាប័នរាជរដ្ឋាភិបាល និងអង្គការជាតិ និងអន្តរជាតិដែលកំពុងបំពេញការងារដើម្បីលើកកម្ពស់សុវត្ថិភាពចរាចរណ៍ឲ្យកាន់តែល្អប្រសើរ ចំណែកឯកុមារកម្ពុជាវិញក៏អាចនឹងត្រូវបានជួយសង្គ្រោះពីការទទួលរងរបួសខួរក្បាល និងមរណភាពដែរ ។

តាមការស្រាវជ្រាវរបស់អង្គការពាក់ព័ន្ធនៅកម្ពុជា បង្ហាញថា៖

១- មានអ្នករួមដំណើរតាមទោចក្រយានយន្តតែ៨% ប៉ុណ្ណោះដែលបានពាក់មួកសុវត្ថិភាព។

២-អ្នករួមដំណើរតាមទោចក្រយានយន្តជាកុមារពាក់មួកសុវត្ថិភាពក្នុងកម្រិតទាបជាងអ្នករួមដំណើរជាមនុស្សពេញវ័យ (តាមការអង្កេតក្នុងចំណោម

ឪពុកម្ដាយរបស់កុមារបានបញ្ជាក់ថា ឪពុកម្ដាយរបស់កុមារជិត៥០% បានរាយការណ៍ថាកូនៗរបស់ពួកគាត់ "**មិនធ្លាប់ពាក់មួកសុវត្ថិភាពទេ**" ទោះបីជាតាមជាក់ស្តែង កុមារទាំងនោះក៏អាចប្រឈមនឹងគ្រោះថ្នាក់ដូចមនុស្សពេញវ័យក៏ដោយ)។

៣- អត្រាស្លាប់នៃអ្នករួមដំណើរតាមទោចក្រយានយន្តជិត**២៥%** ជាមនុស្សដែលមានអាយុ១៩ឆ្នាំ និងជាកុមារដែលមានអាយុក្រោម១៩ឆ្នាំ ។

៤-ចំពោះមតិទាក់ទងនឹងសុវត្ថិភាពចរាចរណ៍សាធារណៈ មានតែមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកកម្ពុជាទេ ដែលគេរាយការណ៍ថាជាអជ្ញាធរមានសមត្ថកិច្ចដែលទទួលបានការគោរពជាងគេបំផុត។ ប្រសិនបើវិសោធនកម្មថ្មីនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនេះ តម្រូវឱ្យតែមនុស្សពេញវ័យពាក់មួកសុវត្ថិភាពនោះ វានឹងធ្វើឱ្យមានការយល់ច្រឡំកាន់តែធ្ងន់ធ្ងរថា ផ្នែកក្បាលរបស់កុមារនឹងមិនប្រឈមគ្រោះថ្នាក់ដូចផ្នែកក្បាលមនុស្សពេញវ័យទេ។

យោងតាមបទពិសោធន៍នៅក្នុងប្រទេសវៀតណាមទាក់ទងនឹងការពាក់មួកសុវត្ថិភាពរបស់កុមារបានបង្ហាញគួរឱ្យជឿជាក់ថា ប្រសិនបើមិនបញ្ចូលបទបញ្ញត្តិច្បាស់លាស់ និងតឹងរឹងទាក់ទងនឹងការពាក់មួកសុវត្ថិភាពរបស់កុមារទៅក្នុងច្បាប់ទេ នោះវានឹងនាំឱ្យមានលទ្ធផលប្រកបដោយភាពមហន្តរាយដោយសារការមិនពាក់មួកសុវត្ថិភាពត្រូវបានគេទទួលស្គាល់ថាជា "**ក្រឹត្យក្រម**" និងក្លាយជាទម្លាប់ប្រចាំថ្ងៃ។ នៅប្រទេសវៀតណាម អត្រាកុមារពាក់មួកសុវត្ថិភាពនៅតែបន្តធ្លាក់ចុះរហូតដល់ ៣០% ដោយសារតែច្បាប់មិនបានបញ្ចូលកុមារដែលមានអាយុក្រោម១៩ឆ្នាំឱ្យពាក់មួកសុវត្ថិភាព និងដោយមានការយល់ខុសជាទូទៅថា កុមារមិនចាំបាច់ពាក់មួកសុវត្ថិភាពទេ។ ប្រសិនបើ កុមារត្រូវបានបញ្ចូលទៅក្នុងច្បាប់ស្តីពីការពាក់មួកសុវត្ថិភាព

ពីជំបូងរបស់ប្រទេសវៀតណាមនោះ ម៉្លេះកុមារដែលមានអាយុចន្លោះពី ០-១៨ឆ្នាំ នឹងត្រូវបានការពារមិនឱ្យស្លាប់រហូតដល់ចំនួន៣៣៨នាក់, របួសធ្ងន់ ៥ ០៧១នាក់ និងរបួសស្រាលចំនួន ២ ៣៦៦នាក់ ហើយថែមទាំងអាចឱ្យរដ្ឋាភិបាលសន្សំថវិកាបានប្រមាណ២៥លានដុល្លារទៀតផង។ ប្រទេសកម្ពុជាក៏អាចទទួលរងនូវបទពិសោធន៍ដូចគ្នានេះដែរ។ ដោយសារចំនួនប្រជាពលរដ្ឋប្រើប្រាស់ទោចក្រយានយន្តកើនឡើងជារៀងរាល់ថ្ងៃ ដូច្នេះស្ថានភាពចរាចរណ៍ផ្លូវគោកនៅប្រទេសកម្ពុជាបានបង្ហាញអំពីការប្រឈមដូចគ្នានឹងប្រទេសវៀតណាម គឺមានផលវិបាកធ្ងន់ធ្ងរដូចគ្នា។

នៅក្នុងរយៈពេលពីរ បីសប្តាហ៍ខាងមុខនេះ **ឯកឧត្តមរដ្ឋមន្ត្រី** នឹងមានឱកាសធ្វើអន្តរាគមន៍យ៉ាងអង់អាច និងប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងការប្រើប្រាស់មួកសុវត្ថិភាពរបស់កុមារ ហើយតាមរយៈអន្តរាគមន៍នេះនឹងជំរុញឱ្យកម្ពុជាក្លាយជាប្រទេសឈានមុខមួយក្នុងការបង្កើតនូវគំនិតថ្មីអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅក្នុងតំបន់។ ការមិនបញ្ចូលកុមារឱ្យនៅក្រោមបទបញ្ញត្តិស្តីពីការពាក់មួកសុវត្ថិភាពនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកពិតជានឹងបន្តធ្វើឱ្យមានការបាត់បង់ជីវិតកុមារគួរឱ្យសោកសង្វេងណាស់ បើទោះបីថាហេតុការណ៍នេះយើងពិតជាអាចការពារបានក៏ដោយ។

សេចក្តីដូចបានជំរាបជូនខាងលើនេះ យើងខ្ញុំសូមស្នើសុំដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពបញ្ចូលបទបញ្ញត្តិស្តីពីមួកសុវត្ថិភាពកុមារទៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងដើម្បីធានាថា កុមារត្រូវបានការពារដោយច្បាប់។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០១១

| | |
|---|---|
| អង្គការមូលនិធិបង្ការរបួស អាស៊ី | អង្គការជនពិការអន្តរជាតិប៊ែលហ្សិក |
| គីម បញ្ញា | យ៉េរ៉ុន ស្កុល |
| នាយកប្រចាំប្រទេសកម្ពុជា | នាយកប្រចាំប្រទេសកម្ពុជា |
| អង្គការក្រុមគ្រូពេទ្យអន្តរជាតិ-កម្ពុជា | សមាគមយានយន្តនៃកម្ពុជា |
| ផាន់ សុជាតិ | ម៉ើ បូរ៉ា |
| អ្នកសម្របសម្រួលគំរោង | នាយកគំរោង |

អង្គការសម្ព័ន្ធដើម្បីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

ស៊ឹម សុផល

នាយកប្រតិបត្តិស្តីទី ៗ